# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៤១៥ ព្ររ.៣.២៦-៩៧

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបចូល**

**លោក ប្រធានតុលាការខេត្ត ក្រុង**

**លោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីសំណុំលិខិតពិនិត្យលទ្ធផលវិភាគកម្រិតជម្ងឺរបេងរបស់ទណ្ឌិត ដែលទាក់ទងនឹងការសុំដោះលែងដោយមានលក្ខខ័ណ្ឌ ឬអនុញ្ញាតឱ្យចេញទៅព្យាបាលនៅក្រៅមន្ទីរឃុំឃាំង ។

កន្លងមកក្រសួងតែងបានទទួលសំណើសុំការអនុញ្ញាតដើម្បីយកទណ្ឌិតទៅព្យាបាលនៅក្រៅមន្ទីរឃុំឃាំងឬក៏សំណុំបែបបទនៃការសុំដោះលែងទណ្ឌិតប្រភេទនេះដោយមានលក្ខខ័ណ្ឌ ដែលត្រូវអនុវត្តតាមមាត្រា៧១នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-០៩-១៩៩២ ។

ខ្ញុំសូមជម្រាបអស់លោកថា ជម្ងឺរបេងបច្ចុប្បន្ននេះមិនមែនជាជម្ងឺធ្ងន់ធ្ងរដូចជម្ងឺអេដស៍ទេ គេអាចព្យាបាលសះជាបានដោយងាយដោយថ្នាំព្យាបាលថ្មីៗនេះមានប្រសិទ្ធិភាពណាស់ ។ ប៉ុន្តែបញ្ហាមួយដែលឱ្យយើងចាប់អារម្មណ៍គឺជម្ងឺ នេះឆ្លងទៅអ្នកនៅជាមួយគ្នា ហើយដោយសព្វថ្ងៃពន្ធនាគាររបស់យើងនៅមានការខ្វះខាតឱ្យទណ្ឌិតនៅរួមជាមួយគ្នា ក្រសួងយុត្តិធម៌បានគិតគូរដល់បញ្ហានេះពេញកម្រិត ។

អស់លោកអាចបញ្ជូនសំណូមពររបស់ប្រធានពន្ធនាគារ បន្ទាប់ពីលោកព្រះរាជអាជ្ញាបានពិនិត្យឃើញជម្ងឺរបស់ទណ្ឌិតកើតជម្ងឺរបេងជាក់ស្តែង ហើយក្រោយពីសុំឱ្យពេទ្យជំនាញបំពេញសំណុំលិខិតពេទ្យ ដោយមានលិខិតកោសល្យ វិច្ឆ័យបញ្ជាក់ច្បាស់លាស់ដូចមានណែកក្នុងលិខិតលេខៈ៣៥៩ មរបហស.៩៧ ចុះថ្ងៃទី០៨-១០-៩៧ របស់គណៈកម្មាធិការមជ្ឈមណ្ឌលជាតិកំចាត់ជម្ងឺរបេង ដែលជូនភ្ជាប់មកជាមួយនេះស្រាប់ដើម្បីស្នើសុំដោះលែងដោយមានលក្ខខ័ណ្ឌ ។

ការដោះលែងឱ្យនៅក្រៅពន្ធនាគារដោយមានលក្ខខណ្ឌ័នេះ គឺត្រូវបញ្ជាក់លើដីកាដោះលែងឱ្យទណ្ឌិតមកបង្ហាញខ្លួនមួយខែម្តង ។ បើមានការមានៈមិនអនុវត្តតាមគេទេ ត្រូវបញ្ចូលមកក្នុងពន្ធនាគារវិញ ។

សូមអស់លោកអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យបានត្រឹមត្រូវបំផុត ។ ខ្ញុំសូមបញ្ជាក់ថាការស៊ីគ្រលំ ឬការក្លែងបន្លំឈ្មោះអ្នកម្ចាស់កំហាក ឬអ្នកម្ចាស់ឈាម (បើជាជម្ងឺអេដស៍ ឬជម្ងឺគ្រុនចាញ់។ល។) ដើម្បីដោះលែងមនុស្សទោសជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ហើយក្រសួងយុត្តិធម៌គ្មានសិទ្ធិអត់អោនឱ្យទេ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- គណៈកម្មការការពារសិទ្ធិមនុស្ស-រដ្ឋសភា
- ក្រសួងសុខាភិបាល
- មន្ទីសុខាភិបាលក្រុងភ្នំពេញ
- ដើម្បីជ្រាប